**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៦៩០.....សហវ

**ប្រកាស**

**ស្តីពី**

**ការអនុញ្ញាតឱ្យប្រើប្រាស់កម្មវិធីកាត់បន្ថយអត្រាពន្ធគយ**
**០-៥ ភាគរយនៃបន្ទាត់ពន្ធគយសំរាប់បង្គ្រប់ ៨០ភាគរយនៃបញ្ជីដាក់បញ្ចូល**
**ដែលជាកាតព្វកិច្ចរបស់កម្ពុជាក្រោមផែនទីសមាហរណកម្មអាស៊ាន**

........................

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញភាពចាំបាច់ក្នុងការបំពេញកាតព្វកិច្ចរបស់កម្ពុជាដែលមានចែងនៅក្នុងផែនទីសមាហរណកម្មអាស៊ាន

Downloaded from http://www.khmerlaws.com

## សំរេច

**ប្រការ១** : ប្រកាសឱ្យប្រើប្រាស់ការកាត់បន្ថយអត្រាពន្ធគយដែលជាកាតព្វកិច្ចរបស់កម្ពុជាក្រោមផែនទីសមាហរណកម្មអាស៊ាន

**ប្រការ២** : ដើម្បីប្រសិទ្ធិភាពនៃការអនុវត្តន៍កាតព្វកិច្ចនានាដែលមាននៅក្នុងផែនទីសមាហរណកម្មអាស៊ាន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងចេញប្រកាសណែនាំជាបន្តបន្ទាប់។

**ប្រការ៣** : ប្រកាសនេះ ចាប់មានប្រសិទ្ធិភាពអនុវត្តពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៨ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៨

គាត ឈន់

ចម្លងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ខេត្ត ក្រុង
  "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
  "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

Downloaded from http://www.khmerlaws.com